**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...១១...ស.ស.រ**

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារធ្វើបដិកោសល្យវិច្ឆ័យ និងស្រាវជ្រាវ លើករណីវិវាទដីធ្លី ចំនួន ១៥៥ ហិកតា ស្ថិតនៅក្នុងឃុំឈ្វាំង ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៦៩៩ / ០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៦៩៩ / ០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៨០១ / ១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារធ្វើបដិកោសល្យវិច្ឆ័យ និងស្រាវជ្រាវ លើករណីវិវាទដីធ្លី ចំនួន ១៥៥ ហិកតា ស្ថិតនៅក្នុងឃុំឈ្វាំង ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល រួមមានសមាសភាពដូចខាងក្រោម :

១- លោក **នុត ស៊ីធមី** អភិបាលស្រុកពញាឮ ប្រធាន

www.pheakdeylaw.com

២- លោក **ឈឹម គន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល អនុប្រធាន

៣- លោក **ចាន់ សុខមករា** ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុកពញាឮ សមាជិក

៤- លោក **ម៉ៅ សម** មេឃុំជ្រៃលាស់ សមាជិក

៥- លោក **អ៊ី ភារិន** មេឃុំឈ្វាំង សមាជិក

៦- លោក **ថេង ម៉ុនតេង** មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៧- លោក **ឡូន សុផាន់ណា** មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សមាជិក

**ប្រការ ២** : ក្រុមការងារធ្វើបដិកោសល្យវិច្ឆ័យ និងស្រាវជ្រាវ លើករណីវិវាទដីធ្លី ចំនួន ១៥៥ ហិកតា ស្ថិតនៅក្នុងឃុំឈ្វាំង ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល មានភារកិច្ចដូចតទៅ :

- ធ្វើបដិកោសល្យវិច្ឆ័យទៅលើរបាយការណ៍របស់ក្រុមអធិការកិច្ចសាលាខេត្តកណ្តាល
- ប្រមូលព័ត៌មានឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ទាក់ទងនឹងផ្ទៃដីវិវាទខាងលើ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារដែលសម្រេចបាន ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សាលាខេត្តកណ្តាល សាលាស្រុកពញាឮ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com